**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០០២ សហវ.

រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ២០០៧

# សារាចរណែនាំ

## អនុវត្តន៍ប្រកាសស្តីពី
## ការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និង អាជ្ញាប័ណ្ណ
## ផ្នែកសេវាកម្មវាយតំលៃ និង សេវាកម្មអចលនវត្ថុ

សារាចរណែនាំនេះត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃលិខិតបទដ្ឋានដូចតទៅ ÷

- ព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ ២០០៧
- អនុក្រឹត្យលេខ ៧៨ អនក្រ/បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០០ ស្តីពីការបំពេញបន្ថែម និងកែសំរួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ចំណារឯកភាពរបស់សម្តេចនាយករដ្ឋមន្ត្រីចុះថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០៥ លើលិខិតលេខ ៤១៥៧ សហវ. ចុះថ្ងៃ ទី ១១ ខែ កក្កដា ឆ្នាំ ២០០៥
- ប្រកាសលេខ ៥៨៤ សហវ.ប្រក ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការកែសម្រួលការរៀបចំ និង ការប្រព្រឹត្តទៅនៃនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ប្រកាសលេខ ១៥២ សហវ.ប្រក.ឧហ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនបត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណផ្នែកសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ
- តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

ក្នុងគោលបំណងឈានទៅរកការគ្រប់គ្រងសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុដែលកំពុងតែធ្វើប្រតិបត្តិការក្នុងព្រះរាជាណាចក្រកម្ពុជា ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សំរេចចេញសារាចរណែនាំអនុវត្តន៍ប្រកាស លេខ ១៤២ សហវ.ប្រក.ឧហ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណផ្នែកសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ ដែលមានខ្លឹមសារដូចតទៅ÷

## ១. និយមន័យ

**ក.** សេវាកម្មអចលនវត្ថុ ដែលមានចែងក្នុងប្រការ ២ នៃប្រកាសលេខ ១៤២ សហវ. ប្រក.ឧហ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណសំដៅដល់÷

- អាជីវកម្ម ដែលធ្វើឡើងដោយក្រុមហ៊ុន លើការទិញ លក់ សាងសង់សំរាប់លក់ ជួល បញ្ចាំ ដីធ្លី ផ្ទះសំបែង ដែលជាទ្រព្យសម្បត្តិផ្ទាល់របស់ក្រុមហ៊ុន ។
- អាជីវកម្ម ដែលធ្វើឡើងដោយក្រុមហ៊ុន លើការទិញ លក់ ជួល បញ្ចាំ ដីធ្លី ផ្ទះសំបែង ដែលឈរលើមូលដ្ឋានកិច្ចសន្យា ឬកំរៃ ។ ក្នុងន័យនេះ អាជីវកម្ម សំដៅដល់ សេវាកម្មដែលក្រុមហ៊ុនធ្វើឡើងដើម្បីទទួលបានកំរៃជើងសារក្នុងការទិញ លក់ ជួល បញ្ចាំ ទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់អតិថិជនដែលជារូបវន្តបុគ្គល ឬនីតិបុគ្គល ។

**ខ.** សេវាកម្មវាយតំលៃអចលនវត្ថុ សំដៅដល់ ការវាយតំលៃអចលនវត្ថុដែលធ្វើឡើងត្រឹមត្រូវតាមជំនាញ និងក្រមវិជ្ជាជីវៈ ដោយមានការទទួលខុសត្រូវលើតំលៃអចលនវត្ថុស្របតាមតំលៃទីផ្សារ ។ ការវាយតំលៃអចលវត្ថុត្រូវធ្វើឡើងដោយភាពឯករាជ្យ មិនមានការក្លែងបន្លំ មិនមានភាពលំអៀង និងមិនធ្វើអោយមានការយល់ខុសលើតំលៃអចលនវត្ថុ ដែលបានវាយតំលៃ ។

## ២. ការធ្វើអាជីវកម្មរបស់ក្រុមហ៊ុនដោយគ្មានអាជ្ញាប័ណ្ណ

យោងតាមប្រការ ១៤ នៃប្រកាសលេខ ១៤២ សហវ.ប្រក.ឧហ ចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណផ្នែកសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ ក្រុមហ៊ុនណាដែលផ្តល់សេវាកម្មវាយតំលៃ ឬសេវាកម្មអចលនវត្ថុ ដូចអត្ថន័យបញ្ជាក់ខាងលើដោយគ្មានអាជ្ញាប័ណ្ណពីក្រសួង ត្រូវទទួលការផាកពិន័យជាទឹកប្រាក់ចំនួន ១០ លានរៀល (ដប់លានរៀល) ។ ក្នុងករណីនៅតែបន្តធ្វើអាជីវកម្មដោយពុំព្រមមកដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុទេនោះ ក្រុមហ៊ុនត្រូវទទួលការផាកពិន័យទ្វេដងគឺ ២០ លានរៀល (ម្ភៃលានរៀល) និងត្រូវបិទអាជីវកម្មជាបន្ទាន់ ហើយត្រូវមកបំពេញបែបបទស្នើសុំអាជ្ញាប័ណ្ណពីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។ ករណីមិនអនុវត្តតាមនេះ ក្រសួងនឹងចាត់វិធានការតឹងរឹងទៅតាមផ្លូវច្បាប់ជាធរមាន ។

ចំពោះប្រាក់ផាកពិន័យ គឺត្រូវបង់ដោយផ្ទាល់ទៅរតនាគារជាតិ តាមដីកាអមរបស់នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

**៣. សុពលភាពនៃសារាចរ**

សារាចរនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទទួលបានសារាចរណែនាំនេះ អគ្គលេខាធិការ នាយកខុទ្ទកាល័យ នាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ នាយកដ្ឋានពន្ធដារ និងនាយកដ្ឋានពាក់ព័ន្ធដទៃទៀត ក្រោមឱវាទ និងក្រុមហ៊ុនវាយតំលៃ ក្រុមហ៊ុនអចលនវត្ថុដែលកំពុងធ្វើសេវាកម្មវាយតំលៃ ឬសេវាកម្មអចលនវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់ត្រូវយកចិត្តទុកដាក់ខ្ពស់ក្នុងការអនុវត្តតាមប្រកាសលេខ ១៤២ សហវ.ប្រក.ឧហចុះថ្ងៃទី ១៣ ខែ កុម្ភៈ ឆ្នាំ ២០០៧ ស្តីពីការផ្តល់វិញ្ញាបនប័ត្រវិជ្ជាជីវៈ និងអាជ្ញាប័ណ្ណ ផ្នែកសេវាកម្មវាយតំលៃ និងសេវាកម្មអចលនវត្ថុ និងសារាចរណែនាំនេះ អោយមានប្រសិទ្ធភាពខ្ពស់ ។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន :**

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ដូចក្នុងចំណុច ៣ ដើម្បីសហការអនុវត្ត
-ឯកសារ-កាលប្បវត្តិ